RÉPUBLIQUE FRANÇAISE
*Liberté*
*Égalité*
*Fraternité*

INSTITUT FRANÇAIS
*Liberté*
*Créativité*
*Diversité*

# លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មផ្នែកការប្រលងរបស់វិទ្យាស្ថានបារាំងនៅកម្ពុជា

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះរួមបញ្ចូលដោយភាគីវិទ្យាស្ថានបារាំងដែលមានទីតាំងនៅភ្នំពេញ(កម្ពុជា)មានឈ្មោះថា"IFC"និងភាគីម្ខាងទៀតជារូបវន្តបុគ្គលឬជានីតិបុគ្គលដែលប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងមានឈ្មោះថា "អតិថិជន"។

## គោលបំណង

លក្ខខណ្ឌទូទៅនេះមានគោលបំណងកំណត់ទំនាក់ទំនងកិច្ចសន្យារវាងIFCរួមទាំងលក្ខខណ្ឌអនុវត្តទាំងឡាយចំពោះការទិញ/ប្រើប្រាស់សេវាកម្មដោយអតិថិជនជាលក្ខណៈអាជីពក្តីឬមិនមែនអាជីពក្តី។
សេវាកម្មរបស់ IFC ត្រូវបានផ្តល់ជូននៅទូទាំងប្រទេសកម្ពុជាដោយក្រុមការងាររបស់ IFC។
ការទទួលបានទំនិញឬសេវាកម្មពី IFC
មានន័យថាអតិថិជនបានយល់ព្រមទាំងស្រុងនូវលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្ម។
លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះគ្របដណ្តប់លើលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌដោយឡែកដែលមិនបានចែងច្បាស់លាស់ដោយ IFC ។

IFC រក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌទូទៅនៃការលក់សេវាកម្មរបស់ខ្លួននៅពេលណាក៏បាន។
ក្នុងករណីនេះ
អតិថិជននឹងត្រូវចុះហត្ថលេខាលើលក្ខខណ្ឌទូទៅនៃការលក់ទាំងនេះម្តងទៀតនៅពេលចុះឈ្មោះលើកក្រោយ។ សេវាកម្មផ្តល់ជូនដូចមានក្នុងគេហទំព័ររបស់ IFC : www.ifcambodge.com សេវាកម្មផ្តល់ជូនដោយ IFCមានបីផ្នែក : មជ្ឈមណ្ឌលភាសា, បណ្ណាល័យ និងផ្នែកវប្បធម៌។ ចំពោះផ្នែកបណ្ណាល័យ និងផ្នែកវប្បធម៌ លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនិងត្រូវអនុវត្តតាមករណីនីមួយៗនិងត្រូវទំនាក់ទំនងតាមពេលវេលាសមស្រប។សម្រាប់សេវាកម្មទាំងអស់ដែលស្ថិតនៅក្រោមលក្ខខណ្ឌទូទៅនេះតម្លៃដែលបង្ហាញនៅលើគេហទំព័រគឺគិតជាដុល្លារអាមេរិក។

## **Article 1 -** ការវាស់ស្ទង់កម្រិតភាសា

### **A.** លក្ខខណ្ឌទូទៅ

វិទ្យាស្ថានមានរៀបចំការប្រលងវាស់ស្ទង់កម្រិតភាសាបារាំងដែលធ្វើតាមការសរសេរលើក្រដាសផ្ទាល់តែប៉ុណ្ណោះ ដូចជា ប្រលងយកសញ្ញាប័ត្រ DELF Prim, DELF Junior, DELF/DALF Tout Public, TCF Tout Public, TCF Canada, TCF Québec និង TCF IRN, TEF IRN, TEF Canada, TEF Québec និង TEF AU ការប្រលងវាស់ស្ទង់កម្រិតភាសាបារាំងDFPជំនួញទំនាក់ទំនងអន្តរជាតិសុខាភិបាលនិងទេសចរណ៍-សណ្ឋាគារ-ភោជនីយដ្ឋា ន ត្រូវប្រលងតាមកុំព្យូទ័រ។

### **B.** ការចុះឈ្មោះប្រលង

បេក្ខជនអាចចុះឈ្មោះតាមអនឡាញ(www.ifcambodge.com)ឬចុះឈ្មោះដោយផ្ទាល់នៅមណ្ឌលប្រលង។

រាល់ការចុះឈ្មោះគឺសម្រាប់តែបុគ្គលម្នាក់ៗ
មិនអាចផ្ទេរឲ្យបុគ្គលផ្សេងបានទេហើយអាចធ្វើទៅបានក្នុងអំលុងពេលចុះឈ្មោះតែប៉ុណ្ណោះ។
បេក្ខជនស្នាក់នៅបរទេសដែលចង់ចុះឈ្មោះពីចម្ងាយត្រូវបំពេញបែបបទនិងទូទាត់ថ្លៃចុះឈ្មោះប្រលងឲ្យបានយ៉ាងយូរមួយសប្តាហ៍មុនកាលបរិច្ឆេទឈប់ទទួលចុះឈ្មោះ។

ការសុំប្តូរកម្រិតសុំដកប្រាក់ឬសុំព្យួរការប្រលងនឹងមិនអាចធ្វើទៅបាននោះទេក្រោយពីរដូវកាលចុះឈ្មោះត្រូវបានបញ្ចប់។

ចំពោះការចុះឈ្មោះនៅមណ្ឌលប្រលងបាត់ដំបងនិងសៀមរាបសូមអានលក្ខខណ្ឌទូទៅនៃការលក់របស់មណ្ឌលប្រលងទាំងនោះ។

## C. ការសុំព្យួរឬសុំដកប្រាក់វិញ

ការសុំប្តូរកម្រិតសុំដកប្រាក់ឬសុំព្យួរការប្រលងនឹងមិនអាចធ្វើទៅបាននោះទេក្រោយពីរដូវកាលចុះឈ្មោះត្រូវបានបញ្ចប់។

ចំពោះពាក្យសុំព្យួរពាក់ព័ន្ធនឹងករណីចាំបាច់អតិថិជនសូមភ្ជាប់មកជាមួយនូវឯកសារមានសុពលភាព។
អតិថិជនមិនមានសិទ្ធិសុំក្រោយពេលដែលលិខិតកោះប្រលងបានផ្ញើទៅឲ្យគាត់ហើយនោះទេ។

## D. របៀបបង់ថ្លៃចុះឈ្មោះប្រលង

ការចុះឈ្មោះប្រលងគឺចាត់ចូលជាផ្លូវការបន្ទាប់ពីបេក្ខជនបានឯកភាពលើលក្ខខណ្ឌទូទៅនៃការលក់។
ការទូទាត់ថ្លៃប្រលងគឺត្រូវធ្វើឲ្យបានមុនថ្ងៃដែលកំណត់ដោយវិទ្យាស្ថានបារាំងនៃកម្ពុជា។
បេក្ខជនអាចទូទាត់ដោយបង់ប្រាក់សុទ្ធនៅធនាគារដៃគូតាមកាតធនាគារតាមការផ្ទេរប្រាក់ពីធនាគារឬតាមរយៈកម្មវិធីផ្ទេរប្រាក់តាមទូរស័ព្ទដៃទៅធនាគារដៃគូជាប្រាក់ដុល្លារឬជាលុយរៀល។
បេក្ខជនត្រូវបង់ថ្លៃប្រលងទាំងអស់ក្នុងពេលតែមួយ។

## E. លិខិតកោះប្រលង

កាលបរិច្ឆេទប្រលងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រវិទ្យាស្ថាន
https://ifcambodge.com/examens-et-certifications/និងនៅលើពាក្យចុះឈ្មោះប្រលង។
វិទ្យាស្ថាននឹងផ្ញើលិខិតកោះប្រលងតាមអ៊ីមែលដល់បេក្ខជន។
លិខិតកោះប្រលងនេះបញ្ជាក់ពីថ្ងៃនិងម៉ោងប្រលងផ្លូវការនៃវិញ្ញាសានិមួយៗ។
បេក្ខជនត្រូវត្រៀមលក្ខណៈចាំបាច់ដើម្បីធ្វើយ៉ាងណាអាចមកប្រលងតាមកាលបរិច្ឆេទដូចដែលមាននៅលើលិខិតកោះប្រលងស្រាប់។ ក្នុងករណីអវត្តមានពេលប្រលង អតិថិជនមិនអាចសុំដកប្រាក់វិញបានទេ។

## F. ថ្ងៃប្រលង

បេក្ខជនត្រូវបង្ហាញលិខិតសម្គាល់ខ្លួនផ្លូវការ(សំណៅដើម)ដែលមានប្រសិទ្ធិភាពជាមួយនិងលិខិតកោះប្រលងជាក្រដាសនៅពេលមកប្រលង។  បេក្ខជនត្រូវប្រើប៊ិចពណ៌ខ្មៅឬខៀវនៅពេលប្រលង។

បេក្ខជនមិនត្រូវបានអនុញ្ញាតឲ្យសួរគ្នាឬសួរអ្នកខាងក្រៅនិងផ្លាស់ប្តូរឯកសារគ្នាបានទេ។រាល់ការប្រព្រឹត្តខុសឆ្គងនឹងត្រូវទទួលពិន័យ។

### G. លទ្ធផលប្រលងនិងសញ្ញាប័ត្របណ្ដោះអាសន្ន

មណ្ឌលប្រលងនឹងផ្ដល់ដំណឹងដល់បេក្ខជនតាមFacebookនៅពេលចេញលទ្ធផលប្រលងក្នុងរយៈពេល២សប្ដាហ៍ក្រោយថ្ងៃប្រលងចំពោះការប្រលងDELF/DALF និង៩សប្ដាហ៍ចំពោះការប្រលងTCFនិងDFP។ បេក្ខជនអាចមកដកសញ្ញាប័ត្របណ្ដោះអាសន្នបានឬក៏ដកព្រឹត្តិបត្រពិន្ទុក្នុងករណីប្រលងធ្លាក់នៅកន្លែងចុះឈ្មោះឬក៏ស្នើសុំតាមអ៊ីមែល។
ពេលនោះដែរបេក្ខជនក៏អាចសុំធ្វើការកែប្រែព័ត៌មានផ្ទាល់ខ្លួនក្នុងអំលុងពេលមួយសប្ដាហ៍បន្ទាប់ពីថ្ងៃចេញលទ្ធផលប្រលងរួច។ការសុំកែឈ្មោះថ្ងៃខែឆ្នាំនិងទីកន្លែងកំណើតនៅពេលក្រោយនឹងតម្រូវឲ្យបង់ពិន័យ១២ដុល្លារសម្រាប់ធ្វើសញ្ញាប័ត្រថ្មីម្ដងទៀត។

បេក្ខជនដែលមានបំណងតវ៉ាទាក់ទងនិងលទ្ធផលប្រលងមានរយៈពេលមួយខែគិតចាប់ពីថ្ងៃចេញលទ្ធផលប្រលងដែលត្រូវបានផ្សព្វផ្សាយ។ ការតវ៉ាត្រូវធ្វើតាមការសរសេរមកកាន់មណ្ឌលប្រលង certifications@ifcambodge.com។

គណៈវិនិច្ឆ័យគឺជាអធិបតេយ្យភាពការសម្រេចចិត្តរបស់គណៈវិនិច្ឆ័យត្រូវបានកំណត់ជាកំហិត។

បេក្ខជនមិនអាចធ្វើការតវ៉ាចំពោះលទ្ធផលប្រលងបាននោះទេលើកលែងតែក្នុងករណីមានកំហុសឆ្គងខាងផ្នែកសំភារៈឬក៏ភាពមិនប្រក្រតីក្នុងលក្ខខណ្ឌនៃការដំណើរការប្រលង។

### H. សញ្ញាប័ត្រ

សញ្ញាប័ត្ររបស់បេក្ខជនដែលប្រលងជាប់អាចដកយកបាននៅមណ្ឌលភាសានៃវិទ្យាស្ថានបារាំងយ៉ាងយូរបំផុត៩ខែបន្ទាប់ពីការប្រលងត្រូវបានបញ្ចប់។
សញ្ញាប័ត្រដែលបេក្ខជនមិនមកដកនឹងត្រូវកម្ទេចចោលក្នុងរយៈពេល៥ឆ្នាំក្រោយ។

## **Article 2 -** កម្មសិទ្ធិបញ្ញា

ម៉ាក ឈ្មោះវិស័យ ផលិតផល កម្មវិធីកុំព្យូទ័រ រូបភាព វីដេអូ អត្ថបទ ឬគ្រប់ព័ត៌មានគ្រប់ឯកសារទាំងអស់សុទ្ធសឹងជាកម្មសិទ្ធិបញ្ញាផ្ដាច់មុខរបស់វិទ្យាស្ថានបារាំងតែមួយប៉ុណ្ណោះ។ រាល់ការចំលង ការកែប្រែ ការប្រើប្រាស់ ផ្នែកណាក៏ដោយដើម្បីហេតុផលអ្វីក៏ដោយត្រូវបានហាមឃាត់ជាដាច់ខាត។

ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវសេវាអេឡិចត្រូនិចនៃសារព័ត៌មាននៅវិទ្យាស្ថានដែលបានផ្ដល់ជូនអតិថិជន គ្មាននរណាម្នាក់មានសិទ្ធិយកទៅបង្កើតថ្មីធ្វើអាជីវកម្មផ្សព្វផ្សាយឬផ្សាយបន្តទោះជាមួយផ្នែកណាក៏ដោយនូវរាល់ឯកសារដូចជាកម្មវិធីកុំព្យូទ័រឬរូបភាពឬឯកសារសំលេងដែលវិទ្យាស្ថានបានដាក់ឱ្យប្រើប្រាស់។

## **Article 3 –** ច្បាប់ថតរូបនិងទិន្នន័យផ្ទាល់ខ្លួន

វិទ្យាស្ថានរក្សាសិទ្ធិសុំព័ត៌មានពីអតិថិជន។តាមរយៈការឯកភាពលើឯកសារនេះ

RÉPUBLIQUE FRANÇAISE
*Liberté
Égalité
Fraternité*

INSTITUT FRANÇAIS — *Liberté Créativité Diversité*

អតិថិជនៈការបញ្ចូលព័ត៌មានការគ្រប់គ្រងអាស័យដ្ឋានសារអេឡិចត្រូនិច

អនុញ្ញាត្តិឲ្យវិទ្យាស្ថានប្រើប្រាស់ទិន្នន័យអតិថិជនដែលចុះឈ្មោះស្នើសុំទិដ្ឋាការ។

អនុញ្ញាត្តិឲ្យវិទ្យាស្ថានផ្តល់ទិន្នន័យពេលអ្នកចុះឈ្មោះទៅធនាគារដៃគូABAដែលគោរពតាមច្បាប់

រក្សាការសម្ងាត់ដោយធនាគារដើម្បីឲ្យអតិថិជនអាចប្រើប្រាស់សេវាផ្ទេរប្រាក់តាមទូរស័ព្ទដៃរបស់ABAបាន។
អនុញ្ញាត្តិឱ្យវិទ្យាស្ថានប្រើប្រាស់រូបភាពរបស់ខ្លួននៅតាមគេហទំព័រនិងតាមឯកសារផ្សព្វផ្សាយរបស់វិទ្យាស្ថានក្នុងក្របខ័ណ្ឌគរុកោសល្យតែប៉ុណ្ណោះ។អតិថិជនមានសិទ្ធិចូលមើលនិងកែប្រែទិន្នន័យរបស់ខ្លួនផងដែរ។

## **Article 4 -** ករណីជម្លួ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាត្រូវចំណុះក្រោមច្បាប់ក្នុងស្រុកនៃប្រទេសកម្ពុជា។ក្នុងករណីមានជម្លោះណាមួយ គូវិវាទត្រូវដោះស្រាយចំពោះមុខច្បាប់ក្នុងស្រុក។